**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

# សេចក្តីប្រកាសព័ត៌មាន

ថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលព័ត៌មានថា មានឈ្មួញខិលខូច រៀបចំវិធានការមិនស្របច្បាប់ និងខុសក្រឹត្យក្រមទីផ្សារសេរី ធ្វើឱ្យប្រជាជនបាត់ឱកាសក្នុងការលក់កសិផលនានា ជាពិសេសស្រូវ តាមតម្លៃទីផ្សារពិតប្រាកដ ហើយតម្រូវឱ្យលក់តាមតម្លៃថោក ដែលឈ្មួញទាំងនោះបានកំណត់។

ចំពោះករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់មន្ទីរកសិកម្មទាំងអស់ ត្រូវសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ធ្វើការចុះពិនិត្យ តាមដានស៊ើបអង្កេតដោយមនសិការទទួលខុសត្រូវខ្ពស់បំផុត និងចាត់វិធានការឱ្យបានម៉ឺងម៉ាត់ស្របតាមនីតិវិធីជាធរមាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៥

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**